ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ.....៣១៦២.....អពដ

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ១០ ឆ្នាំ២០១៧

**ជម្រាបជូន**
**លោកនាយកអង្គការ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា**
(Cooperation Committee for Cambodia)
អាសយដ្ឋាន÷ ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦ សង្កាត់ទួលទំពូង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ

**កម្មវត្ថុ÷** ស្តីពីសំណូមពរមួយចំនួនរបស់អង្គការ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា នាកិច្ចប្រជុំពិភាក្សាអំពីកាតព្វកិច្ចសារពើពន្ធរបស់អង្គការ និងសមាគមកម្ពុជា កាលពីថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៧។

**យោង÷**
- ច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ និងធ្វើវិសោធនកម្មបន្តបន្ទាប់
- លិខិតលេខ ០២២៩ គសក/២០១៧ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៧ របស់អង្គការ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា
- កិច្ចប្រជុំពិភាក្សារវាងតំណាងអគ្គនាយកដ្ឋានពន្ធដារ និងអង្គការ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា អំពីកាតព្វកិច្ចសារពើពន្ធរបស់អង្គការនិងសមាគមកម្ពុជា កាលពីថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៧។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោកនាយកជ្រាបថា ពាក់ព័ន្ធនឹងសំណូមពរមួយចំនួនរបស់អង្គការ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា នាកិច្ចប្រជុំពិភាក្សាអំពីកាតព្វកិច្ចសារពើពន្ធរបស់អង្គការនិងសមាគមកម្ពុជា កាលពីថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៧ អគ្គនាយកដ្ឋានពន្ធដារ សូមបញ្ជាក់ជូនតាមចំណុចនីមួយៗ ដូចខាងក្រោម÷

**១. ការស្នើសុំលើកលែងពិន័យទោសទណ្ឌក្នុងការខកខានចុះបញ្ជីពន្ធដារកន្លងមក÷**

អាចអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំលេខ ១៧៧៥៤ អពដ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៧ ស្តីពីការអនុវត្តការលើកទឹកចិត្តផ្នែកពន្ធដារ ចំពោះសហគ្រាសធុនតូច និងសហគ្រាសធុនមធ្យមដែលបានចុះបញ្ជីដោយស្ម័គ្រចិត្ត គឺអនុគ្រោះដោយគ្មានកំណត់ទោសទណ្ឌលើការប្រព្រឹត្តអំពើរាំងស្ទះ ការយឺតយ៉ាវក្នុងការបង់ពន្ធប្រថាប់ត្រា និងពន្ធប៉ាតង់ឡើយ។ ដោយឡែកពាក់ព័ន្ធនឹងប្រភេទពន្ធផ្សេងៗ ទៀត ត្រូវអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**២. ការស្នើសុំលើកលែងអាករលើតម្លៃបន្ថែម÷**

- យោងមាត្រា ៤៣ នៃអនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែម អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ត្រូវបង់អាករលើតម្លៃបន្ថែមចំពោះការទិញទំនិញក្នុងស្រុក ហើយបន្ទាប់មកអាចស្នើសុំបង្វិលសងវិញបាន។ ចំពោះការនាំចូលទំនិញសម្រាប់យកមកប្រើប្រាស់ក្នុងការបំពេញមុខងារជាផ្លូវការរបស់ខ្លួន ត្រូវកំណត់ថាជាការផ្គត់ផ្គង់មិនជាប់អាករ។
- ដោយឡែក អង្គការនិងសមាគមដទៃទៀត ត្រូវមានកាតព្វកិច្ចបង់អាករលើតម្លៃបន្ថែម តាមមាត្រា ៦០ នៃច្បាប់ស្តីពីសារពើពន្ធ លើកលែងតែមានសកម្មភាពមិនស្វែងរកចំណេញដើម្បីបម្រើផលប្រយោជន៍សាធារណៈ ដែលបានទទួលស្គាល់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមមាត្រ ៥៧ កថខណ្ឌ ៧ នៃច្បាប់ស្តីពីសារពើពន្ធ។



អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh

**៣. ការស្នើសុំលើកលែងពន្ធលើប្រាក់ចំណូល÷**

យោងតាមមាត្រា ៩ (ថ្មី) នៃច្បាប់ស្តីពីសារពើពន្ធ ត្រង់កថាខណ្ឌ ខ និងកថាខណ្ឌ គ ដែលចែងថា

*" ប្រាក់ចំណូលលើកលែងពន្ធ÷*

*ខ. ប្រាក់ចំណូលរបស់អង្គការណាមួយដែល÷*

*-ត្រូវបានរៀបចំឡើងនិងដំណើរការសម្រាប់គោលដៅសុទ្ធសាធខាងសាសនា សប្បុរសធម៌ វិទ្យាសាស្ត្រ អក្សរសាស្ត្រឬអប់រំ*

*-គ្មានចំណែកណាមួយនៃទ្រព្យ ឬប្រាក់ចំណូលត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជន។*

*គ. ប្រាក់ចំណូលរបស់អង្គការពលករឬសភាពាណិជ្ជកម្ម ឧស្សាហកម្មឬកសិកម្ម ក្នុងករណីដែលចំណូលរបស់អង្គការទាំងនោះ មិនត្រូវបានប្រើប្រាស់ជាប្រយោជន៍ឯកជនរបស់អ្នកចូលហ៊ុនឬបវត្តបុគ្គល"។*

ផ្អែកលើបទប្បញ្ញត្តិខាងលើ ចំពោះអង្គការ សមាគមដែលមានសកម្មភាព ដែលត្រូវលើកលែងពន្ធលើប្រាក់ចំណូលដូចខាងលើ ត្រូវដាក់ពាក្យស្នើសុំមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីទទួលបានការលើកលែងនេះ។

**៤. ការស្នើសុំបង្កើតក្រុមការងារភាពជាដៃគូរវាងតំណាងអង្គការ និងអគ្គនាយកដ្ឋានពន្ធដារ ដើម្បីដើរតួនាទីក្នុងការដោះស្រាយបញ្ហាប្រឈមនានា ពាក់ព័ន្ធនឹងកាតព្វកិច្ចសារពើពន្ធចំពោះអង្គការនានា÷**

អគ្គនាយកដ្ឋានពន្ធដារឯកភាពតាមសំណើ។

ទន្ទឹមនឹងនេះ អគ្គនាយកដ្ឋានពន្ធដារ សូមណែនាំដល់អង្គការ សមាគមទាំងអស់ឱ្យបំពេញកាតព្វកិច្ចសារពើពន្ធសំខាន់ៗដទៃទៀត ដូចខាងក្រោម÷

ក. ពន្ធកាត់ទុក

ខ. ពន្ធលើប្រាក់បៀវត្ស

គ. ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ

ឃ. ពន្ធលើអចលនទ្រព្យ និង

ង. ដាក់លិខិតប្រកាសនិងបង់ពន្ធប្រចាំខែ ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកនាយកជ្រាប និងសហការអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

សូមលោកនាយកអង្គការ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ទទួលនូវការរាប់អាន ពីខ្ញុំ

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

អគ្គនាយកដ្ឋានពន្ធដារ

**គង់ វិបុល**

**ចម្លងជូន ÷**

- នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
- នាយកដ្ឋានសវនកម្មសហគ្រាស
- អនុក្រុមការងារចុះបញ្ជីពន្ធដារ
  "ដើម្បីជូនជ្រាប-មុខការ"
- ឯកសារ កាលប្បវត្តិ